# ជីវប្រវត្តរបស់ អ៊ីម៉ាំ អាររីដ៏ ض صلوات الله عليه والسلام



សៃយីដ្ធ ម៉ាស៊ូឌី អាយ៉ាទុលឡ៏ហ៊ី

ស្សាគីប បេនបេឌីរ៉ា

الرضا

# បញ្ជីមាតិកា


កំណើត ..... 5

សីលធម៌ត្រចះត្រចង់របស់ព្រះអង្គ صلوات الله عليه والسلام ..... 6

អាកប្បកិរិយាគំរូ ..... 10

- សទ្ធាទានដោយសេចក្ដីគោរព ..... 10
- ប្រយ័ត្នអាការក្រអឺត ..... 12
- ស្ម័ដ្ឋ័ ប្អូនរបស់អ៊ីម៉ាំ صلوات الله عليه والسلام ..... 15

មហាសន្និបាតវិទ្យាសាស្ត្រនៅឯដំណាក់ស្ដេចខ៌្លិហ្វ ..... 19

អ៊ីម៉ាំធ្វើដំណើរទៅកាន់ស្រុកម៉ារ្វ ..... 20

- ឆ្លងកាត់តាមស្រុកម៉ារ្វ ..... 23
- ស្រុកនីស្ហាប៊ូរ(نيشابور) ..... 24
- អព្ភូតហេតុទឹក ..... 26
- ឆ្នាំងស្រុកសាណា អាបាដ់ ..... 27
- ស្រុកទុស(توس) ..... 27
- ស្រុកម៉ារ្វ ..... 29

អ៊ីម៉ាំនិងអំណាច ..... 29

- នមស្ការអ៊ីដ្ទ ..... 31
- គោលដៅរបស់អាល់-ម៉ាក្មុ៎មូន ..... 35

រឿងកវីម្នាក់ ..... 36

- ដ្វាក់ុ៎បាល់ជួបអ៊ីម៉ាំ صلوات الله عليه والسلام ..... 38
- កំណាព្យមួយឃ្លារបស់អ៊ីម៉ាំ صلوات الله عليه والسلام ..... 39
- ជាមួយពួកចោរ ..... 41
- អាវក្រៅរបស់អ៊ីម៉ាំ صلوات الله عليه والسلام ..... 42

ទុក្ករកម្មរបស់អ៊ីម៉ាំ......44
សម្រង់ព្រះវចនៈត្រចះត្រចង់......46
អត្តសញ្ញាណរបស់អ៊ីម៉ាំ صلوات الله عليه والسلام......49



## អត្តសញ្ញាណរបស់អ៊ីម៉ាំ صلوات الله عليه والسلام

*-ព្រះនាម ៖ អ៊ាលី ។*

*-ព្រះនាមចំតើត ៖ អាររីដ្ឋ៍ ។*

*-ព្រះគាវរៈនាម ៖ អាប៊ូ អាល់–ហ្ហាសាន់ ។*

*-ព្រះនាមព្រះបិតា ៖ មូសា អាល់-កាស្ហ៊ីម ។*

*-ថ្ងៃប្រសូត ៖ ១១ ខែ ស៊្ទុល–ក្ល៏អ៊ីដ្ឋាស់ ឆ្នាំទី ១៤៨ សករាជហុ៊ីជ្ជ៉េះត្ថ៍ ។*

*-ថ្ងៃចូលទិវង្គត(ទទួលទុក្ករកម្ម) ៖ ថ្ងៃទី ៣០ ស្វ៏ហ្វារ ឆ្នាំ ២០៣ សករាជ ហុ៊ីជ្ជ៉េះត្ថ៍ ។*

*-កន្លែងបញ្ចុះព្រះរាជសព៖ ស្រុកម៉ាស្ស់ហ្វាដ់ (អតីតស្រុកទុស) ខេត្ត ឃូរ៉សាន ប្រទេសអ៊ីរ៉ន ។*

ٱلْحَمْدُ لِلَّهِ رَبِّ ٱلْعَٰلَمِينَ

21/07/2016





# កំណើត

អ៊ីម៉ាំអាស្ស៊ុលុល-បៃត៏ عليهم السلام ទីប្រាំបី អ៊្មាលី ប៊ិន អ៊ីបរ៉ហ៊ីម អាររីដ្ឋ៏ صلوات الله عليه والسلام បានប្រសូតថ្ងៃទី ១១ ខែ ស៊្មុល-ក៊្កអ៊ីដ្វាស្ស៊ុ ឆ្នាំទី ១៤៨ សកករាជហ៊ិជ្ចរ៉េះត៏្ត នៅឯម៉ាឌ្វីណាស្ស៊ុ ។ ព្រះបិតា صلوات الله عليه والسلام ព្រះអង្គគឺ មូសា ប៊ិន យ៉ាក៊្កហ្វារ صلوات الله عليه والسلام រីឯព្រះមាតាព្រះអង្គជាស្ត្រីមានសទ្ធាស៊ិប់ចិត្ត មានព្រះនាមណាជ្ជម៉ាស្ស៊ុ ។ កាលពីកុមារភាព អ៊ីម៉ាំបានរស់នៅជាមួយព្រះបិតាព្រះអង្គដែលតែងតែឆ្លៀតយកគ្រប់ឱកាសដើម្បីអធិប្បាយប្រាប់បណ្ដាអ្នកស្មោះត្រង់ចំពោះព្រះអង្គថាអត់ពីព្រះអង្គទៅ បុត្រព្រះអង្គជាអ៊ីម៉ាំ ។ អ៊្មាលី ប៊ិន យ៉ាក្ក៊្ដីនបានថា៖ «ខ្ញុំបាននៅឯព្រះរាជដំណាក់ព្រះសន្តបុរស (ពោលគឺ អ៊ីម៉ាំអាល់-កាស្ស៊ឹម صلوات الله عليه والسلام) ពេលអ៊្មាលី صلوات الله عليه والسلام ព្រះរាជបុត្រព្រះអង្គ បានចូលមក ។ ព្រះអង្គមានវចនៈថា៖ «អ៊្មាលី ប៊ិន យ៉ាក្ក៊្ដីនអឺយ បុត្រខ្ញុំនេះជាព្រះបរមគ្រូរបស់បុត្រទាំងឡាយរបស់ខ្ញុំ ។» ហ៊ិស្សាំ ប៊ិន អាល់-ហ្កាកាំបាននៅទីនោះដែរកាលព្រះអង្គបានថ្លែងរឿងនេះ ។ លោកបានថា៖ «ព្រះអង្គបានប្រាប់លោកថាបុត្រព្រះអង្គជាអ៊ីម៉ាំអត់ពីព្រះអង្គទៅ ។»

យើងបានដឹងរួចមកហើយថាអ៊ីម៉ាំ មូសា អាល់-កាស្ស៊ឹម صلوات الله عليه والسلام បានរស់នៅក្នុងស្ថានភាពបែបណាខ្លះ ។ ស្ថានភាពនេះមិនល្អទេសម្រាប់ការប្រកាសជា

សាធារណៈឲ្យដឹងអំពីអ៊ីមុាំដែលស្នង អ៊ីមុាំមូសា អាល់-កាស៊្ឋឹម صلوات الله عليه والسلام នោះ ។ តែអ៊ីមុាំអាស្វ៉លុល-បៃត៍ عليهم السلام ទីប្រាំពីរចេង់ទប់ស្កាត់ជម្លោះ រវាងបណ្ដាអ្នកគាំទ្រព្រះអង្គដោយប្រកាសប្រាប់ពួកគេយ៉ាងច្បាស់លាស់ថា ព្រះរាជបុត្រព្រះអង្គ អ៊ុាលី អារីដ្ហ៏ صلوات الله عليه والسلام ជាអ្នកស្នងព្រះអង្គ ហើយព្រះអង្គបានសូមឲ្យពួកគេលាក់រឿងនេះ ។

## សីលធម៌ត្រចះត្រចង់របស់ព្រះអង្គ صلوات الله عليه والسلام

យើងបានជ្រើសរើសយកមកនូវសេចក្ដីថ្លែងការណ៍មួយចំនួន ដើម្បីអះអាងបញ្ជាក់លក្ខណៈសម្បត្តិវិសេសវិសាល និងសីលធម៌ឥតខ្ចោះរបស់ព្រះអង្គ ។

សេចក្ដីរាយការណ៍ដំបូងទទួលបានពីលោក អ៊ីបរ៉ហ៊ីម ប៊ិន អាល់-អ៊ុាប់បាស់ ដែលបានតំណាលប្រាប់យើងថា៖ «ខ្ញុំមិនដែលឃើញ អាប៊ូ អាល់-ហ្ចាសាន់ អារីដ្ហ៏ صلوات الله عليه والسلام និយាយសោះកក្រោះដាក់អ្នកណា ឬកាត់សម្ដីអ្នកណាម្នាក់ឡើយ ។ ព្រះអង្គមិនដែលបដិសេធជួយអ្នកណាឡើយ កាលណាព្រះអង្គអាចធ្វើបាន ។ ព្រះអង្គមិនដែលសណ្ដូកជើងពីមុខអ្នកណា ព្រះអង្គមិនដែលផ្អែកខ្នងពីមុខអ្នកណាឡើយ ។ ព្រះអង្គមិនដែលជេរអ្នកបម្រើឬទាសៈណា



ក្រោធ អ្នកនោះមិនឃ្លាតឆ្ងាយពីការពិតឡើយ ពេលអ្នកនោះស្កប់ស្កល់ អ្នកនោះមិនធ្លាក់ក្នុងកំហុសឡើយ ពេលអ្នកនោះមានប្រៀបលើគេ អ្នកនោះប្រើអំណាចខ្លួន ។

ត្រូវអាល់-ម៉ាក់មូនបង្ខំឲ្យសោយផ្លែទំពាំងបាយជូរដាក់ថ្នាំបំពុល ។

ឆ្នាំ ២០៣ សករាជហ៊ិជ្រ៉ោះត្ត៍ អ៊ីម៉ាំអារីដ្ឋ៍ صلوات الله عليه والسلام បានចាកចោលលោកនេះ ទៅជួបជុំព្រះបុព្វការី عليهم السلام ព្រះអង្គ ។ សពព្រះអង្គត្រូវបញ្ចុះត្រង់កន្លែងដែលព្រះអង្គបានប្រាប់ហើយនោះនៅឯស្រុកទុស ។

អាល់-ម៉ាក់មូនធ្វើពុតជាមានទុក្ខធំដោយសារមរណកម្មរបស់អ៊ីម៉ាំ បានធ្វើពិធីបុណ្យសពអ៊ីម៉ាំយ៉ាងអធិកអធម ។ នៅក្នុងពិធីបុណ្យសពនេះ អាល់-ម៉ាក់មូនបានដើរជើងទទេ ហាក់ដូចជាចង់ឆ្លើយបដិសេធការចោទប្រកាន់ដែលលេចឮគ្រប់ទិសទីនោះ ។

## សម្រង់ព្រះវចនៈត្រចះត្រចង់

-អ្នកណាមិនអរគុណឪពុកម្ដាយខ្លួនទេ អ្នកនោះមិនអរព្រះគុណអល់ឡោះហ៍ عزّ وجل ទេ ។

-ចំណេះវិជ្ជាប្រសើរបំផុតរបស់មនុស្សគឺការស្គាល់ខ្លួនឯង ។

-អ្នកណាគិតគូរអំពីវិញ្ញាណខ្លួនឯង អ្នកនោះជោគជ័យ ។ អ្នកណាមិនគិតគូរអំពីវិញ្ញាណខ្លួនឯងទេ អ្នកនោះខាតបង់ ។

-កំហឹងជាការក្បង់ពិសោធន៍សម្រាប់អ្នកមានសទ្ធាពីព្រោះ ពេលអ្នកនោះ



ម្នាក់របស់ព្រះអង្គឡើយ ។ ខ្ញុំមិនដែលឃើញព្រះអង្គស្ដោះទឹកមាត់ឡើយ មិនដែលឃើញព្រះអង្គសើចខ្លាំងឡើយ សំណើចរបស់ព្រះអង្គគឺដូចអាការញញឹម ។ ពេលព្រះអង្គសោយព្រះអង្គហៅអ្នកក្បែរព្រះអង្គ រួមទាំងឆ្មាំទ្វារនិងអ្នកថែសេះមកចូលរួមបរិភោគផងដែរ ។ បើអ្នកណាអះអាងថាបានឃើញអ្នកណាម្នាក់ថ្លៃថ្នូរនិងប្រកបដោយសប្បុរសធម៌ដូចព្រះអង្គដែរ កុំជឿអ្នកនោះ ។»

សេចក្ដីរាយការណ៍ទីពីរទទួលបានពីបុគ្គលម្នាក់ដែលបានទៅតាម អ៊ីម៉ាំអារីដ្ឋ៍ صلوات الله عليه والسلام កាលព្រះអង្គយាងទៅឯតំបន់ឃូរ៉សាន (خراسان) ។ លោកបានតំណាលប្រាប់យើងថាពេលកំពុងធ្វើដំណើរ ដល់ពេលបរិភោគ ។ អ៊ីម៉ាំអារីដ្ឋ៍ صلوات الله عليه والسلام បានអញ្ជើញមិត្តទាំងអស់របស់ព្រះអង្គ និងបម្រើទាំងឡាយរបស់ព្រះអង្គ មិនចោលម្នាក់ទេ ។ អ្នកថ្លែងសេចក្ដីរាយការណ៍របស់យើងបានស្នើព្រះអង្គឲ្យទុកតុមួយដោយឡែកសម្រាប់តែបរិវារ ។ អ៊ីម៉ាំមានវចនៈថា៖ «ព្រះជាម្ចាស់ ព្រះដ៏មហាឧត្ដុង្គឧត្ដម ព្រះដ៏មានសិរីសួស្ដី ជាព្រះតែមួយគត់ ។ ឪពុករបស់មនុស្សគឺឪពុកតែមួយគត់ ម្ដាយរបស់មនុស្សក៏ដូច្នោះដែរ ។ ចំណែកឯការតបស្នងនៅលើទង្វើ ។»







# ទុក្ករកម្មរបស់អ៊ីម៉ាំ

សន្តតិវង្សអុាប់បាស់គិតថា នយោបាយរបស់អាល់-ម៉ាក់មូនធ្វើឲ្យពួកគេខូចប្រយោជន៍ ។ ពួកគេមួយចំនួន ដែលពឹងផ្អែកលើ អាល់-អាមីន ប្អូនរបស់អាល់-ម៉ាក់មូននោះ រង់ចាំតែឱកាសល្អដើម្បីទម្លាក់អាល់-ម៉ាក់មូនដែលទុកពួកគេចោលឆ្ងាយអំណាច ។

ការតែងតាំងអ៊ីម៉ាំអាររីដ្ហ៍ صلوات الله عليه والسلام ជាអ្នកស្នងរាជបល្ល័ង្ក ជាឱកាសល្អសម្រាប់ពួកអុាប់បាស់ទាំងអស់ដែលរស់នៅឯស្រុកបាក់ដាដ់ ហើយដែលមិនយល់ស្របនឹងការផ្លាស់ប្តូររាជធានីដោយយកស្រុកម៉ារូជារាជធានីនោះទេ ។ ពួកគេបានប្រជុំគ្នាជុំវិញ អ៊ីបរ៉ហ៊ីម អ៊ីបនូ អាល់-ម៉ាស់ឌី ឪពុកមា(ឬឪពុកធំ)របស់អាល់-ម៉ាក់មូន ដែលជាអ្នកចំរៀង ហើយមិនដែលប៉ុនប៉ងធ្វើនយោបាយនោះទេ ។ ពួកអុាប់បាស់ក៏បានប្តេជ្ញាស្មោះស្ម័គ្រចំពោះអ៊ីបរ៉ហ៊ីមអ្នកចំរៀង ហើយដំណឹងទម្លាក់អាល់-ម៉ាក់មូនក៏បានលេចឮទៅដល់រាជធានីម៉ារូ ។

អាល់-ម៉ាក់មូនយល់ភ្លាមថាមានជម្រើសតែមួយគឺ៖ ស្រុះស្រួលជាមួយត្រកូលអុាប់បាស់វិញដោយធ្វើឃាត អ៊ីម៉ាំអាររីដ្ហ៍ صلوات الله عليه والسلام យ៉ាងរហ័សលើសពីការស្មានទុក ។

ត្រូវគេតែងតាំងជាអ្នកស្នងរាជអស់រយៈពេលមុនពីរឆ្នាំ អ៊ីម៉ាំអាររីដ្ហ៍ صلوات الله عليه والسلام



ថ្ងៃមួយ បុរសម្នាក់បានទូលអ៊ីម៉ាំថា៖ «សូមស្បថចំពោះអល់ឡោះហ៍ عز وجل មិនមានអ្នកណាម្នាក់នៅលើផែនដីនេះ មានបិតាមាតាថ្លៃថ្នូរដូចព្រះបិតាមាតាព្រះអង្គឡើយ ។» អ៊ីម៉ាំមានវចនៈថា៖ «សេចក្តីអាណិតអាសូរបានធ្វើឲ្យព្រះអង្គប្រកបដោយសេចក្តីថ្លៃថ្នូរ ។»

ថ្ងៃមួយបុរសម្នាក់បានទូលព្រះអង្គថា៖ «សូមស្បថចំពោះអល់ឡោះហ៍ عز وجل ព្រះអង្គជាបុគ្គលប្រសើរលើសមនុស្សទាំងឡាយ ។» អ៊ីម៉ាំចង់ទុករឿងនេះជាមេរៀនសម្រាប់មុស្លីមទាំងឡាយគឺ៖ កុំសរសើរអ្នកណាម្នាក់នៅចំពោះមុខអ្នកនោះ ទោះបីអ្នកនោះសមនឹងទទួលការសរសើរពិតមែនក៏ដោយ ។ ហើយព្រះអង្គមានវចនៈថា៖ «ចំណែកអ្នកវិញកុំស្បថ ។ អ្នកណាខ្លាចអល់ឡោះហ៍ عز وجل ជាងខ្ញុំ អ្នកនោះប្រសើរជាងខ្ញុំ ។ សូមស្បថចំពោះអល់ឡោះហ៍ عز وجل អាយ៉ាត់នេះមិនត្រូវលើកចោលទេ៖ "យើងបានបែងចែកពួកអ្នកជាប្រជាជាតិនិងជាកុលសម្ព័ន្ធដើម្បីនឹងឲ្យពួកអ្នកស្គាល់គ្នា ។ ការពិត សម្រាប់អល់ឡោះហ៍ عز وجل អ្នកថ្លៃថ្នូរបំផុតក្នុងចំណោមពួកអ្នកគឺអ្នកដែលជឿស៊ប់ចិត្តបំផុត ក្នុងចំណោមពួកអ្នក (ស៊ិ.៤៩, អា.១៣) ។"»

# អាកប្បកិរិយាគំរូ

អ៊ីមុាំ អារីដ្ហ៊ صلوات الله عليه والسلام ធ្លៀតយកគ្រប់ឱកាសដើម្បីផ្សព្វផ្សាយសិក្ខាបទសីលធម៌អ៊ីស្លាមតាមរយៈអាកប្បកិរិយាច្បាស់លាស់ ដែលអាចដិតជាប់នៅក្នុងអារម្មណ៍មនុស្ស ។ តទៅនេះយើងនឹងលើកយកមកបរិយាយនូវអាកប្បកិរិយាគំរូរបស់អ៊ីមុាំនិងសិក្ខាបទសីលធម៌ ដែលទទួលបានមកពីអ្នកសិក្សាពីប្រវត្តិសៀវភៅនិងអ្នកប្រវត្តិសាស្ត្រមុស្លីម ។

## សទ្ធាទានដោយសេចក្តីគោរព

ខណៈដែលអ៊ីមុាំអារីដ្ហ៊ صلوات الله عليه والسلام កំពុងតែគង់អធិប្បាយច្បាប់សាសនាដល់អ្នកស្តាប់ដ៏ច្រើន បុរសម្នាក់បានដើរចូលមក បានទូលព្រះអង្គថាគាត់ជាអ្នកស្រុកយូរ៉សានដែលត្រឡប់មកពីបំពេញពិធីហាជ្ជវិញ ហើយបានបាត់បង់ទ្រព្យ ។ គាត់សូមឲ្យព្រះអង្គជួយគាត់ដើម្បីទៅកាន់លំនៅដ្ឋានគាត់ ដោយសន្យាថាលុះដល់ផ្ទះវិញ គាត់នឹងដាក់ទានក្នុងព្រះនាមអ៊ីមុាំដែលស្មើនឹងជំនួយរបស់ព្រះអង្គ ។ អ៊ីមុាំអារីដ្ហ៊ صلوات الله عليه والسلام សូមឲ្យគាត់អង្គុយចុះ អធិប្បាយបន្ត ។

លុះប្រជុំចប់ បុរសស្រុកយូរ៉សាននៅតែឯងជាមួយអ្នកជំនិតរបស់អ៊ីមុាំ ។





ដែលដង្វាក់ប៉ាល់ទើបនឹងបានសូត្រជាគ្រាដំបូងឲ្យអ៊ីម៉ាំស្តាប់ ។

## អាវក្រៅរបស់អ៊ីម៉ាំ صلوات الله عليه والسلام

លុះដង្វាក់ប៉ាល់បានមកដល់ស្រុកគុម ពួកយុវជនសូមទិញអាវក្រៅដែលអ៊ីម៉ាំអារីដ្ហ صلوات الله عليه والسلام បានឲ្យលោក ដោយហ៊ានឲ្យថ្លៃដល់ទៅមួយពាន់ឌីណារ ។ ដង្វាក់ប៉ាល់បដិសេធ តែនៅតាមផ្លូវពួកគេបានកញ្ឆក់យកអាវនោះពីលោក បានបង្ខំឲ្យលោកព្រមធ្វើការដូរញដូរ ។ នៅទីបំផុត លោកយល់ព្រមដោយដាក់លក្ខខណ្ឌឲ្យគាត់អាវនោះមួយអន្លើតូចឲ្យលោកទុកជាអនុស្សាវរីយ៍ ។

លុះដង្វាក់ប៉ាល់បានមកដល់ផ្ទះវិញ ភរិយាលោកមានជម្ងឺភ្នែក ។ គ្រូពេទ្យទាំងអស់គិតថាគាត់ច្បាស់ខ្វាក់ភ្នែក ។ ដង្វាក់ប៉ាល់ផុសគំនិត យកកំណាត់អាវក្រៅអ៊ីម៉ាំទៅរុំលើភ្នែកភរិយាលោក ។ អស់រយៈពេលមួយយប់ ភរិយាលោកជាដាច់ពីជម្ងឺភ្នែកវិញ ។

គុណបុណ្យ អ៊ីម៉ាំអារីដ្ហ صلوات الله عليه والسلام អាចធ្វើឲ្យជម្ងឺដែលពួកគ្រូពេទ្យបានគិតថាមិនអាចព្យាបាលជាទេនោះទៅជាជាសះស្បើយវិញដូច្នេះឯង ។





អ៊ីម៉ាំបានចូលទៅក្នុងបន្ទប់ ហើយចេញមកវិញជាមួយថង់ថវិកាមួយដែលព្រះ
អង្គហុចឲ្យទៅបុរសស្រុកឃូរ៉សានពីខាងក្រោយរាំងនន ហើយប្រាប់គាត់ថា៖
«នេះគឺប្រាក់ពីរយឌីណារសម្រាប់ចាយវាយក្នុងពេលធ្វើដំណើរ ។ ចូរ
លោកកុំដាក់ទានក្នុងនាមខ្ញុំ ។» បុរសស្រុកឃូរ៉សានបានចាកចេញទៅដោយ
អរព្រះគុណអ៊ីម៉ាំ តែទង្វើរបស់អ៊ីម៉ាំបានធ្វើឲ្យជំនិតទាំងឡាយឆ្ងល់អនេក ។
ជំនិតម្នាក់បានសួរព្រះអង្គថា៖ «ព្រះរាជបុត្ររ៉ស៊ូលុលឡោះហ្វ៍អឺយ ហេតុអ្វី
ព្រះអង្គលាក់មុខមិនឲ្យបុរសនោះឃើញ ?» អ៊ីម៉ាំបានតបថា៖ «ព្រោះខ្ញុំមិន
ចង់ឃើញសេចក្តីខ្មាស់អៀននៅលើមុខបុរសនេះ ពេលគាត់សូម ។ លោក
មិនបានឮហាឌីស្ទរបស់ព្រះសាស្តា صلى الله عليه وآله وسلم ទេ គឺ៖ "ការដាក់ទានដោយលាក់បាំង
ស្មើនឹង ៧០ ពិធីហាជ្ជ ។"»

## ប្រយ័ត្នអាការក្រអឺត

អាស្ម៉ាង់ អាល់-ប៊ីស្ទាន់ទីជាអ្នកប្រាជ្ញដ៏ល្បីមួយរូបដែលបានចរចាឆ្លើយ
ឆ្លងជាមួយអ៊ីម៉ាំ អារីដ្ហ៍ صلوات الله عليه والسلام តាមរយៈសំបុត្រយ៉ាងច្រើន ។ បន្ទាប់មក លោក
ព្រមទទួលស្គាល់ថាព្រះអង្គមានអំណាចខាងសាសនា និងជាអ៊ីម៉ាំស្រប
ច្បាប់ ។ លោកផ្តល់ជាអ្នកធ្វើសេចក្តីរាយការណ៍ប្រាប់យើងថា៖ «អ៊ីម៉ាំអារីដ្ហ៍



ខ្សឹកខ្សួល ។ លុះដ្វាក្ក់បាល់បានសូត្រកំណាព្យចប់ អ៊ីម៉ាំបានថ្លែងអំណរគុណ
យ៉ាងជ្រាលជ្រៅហើយបានប្រទានអំណោយឲ្យលោក តែលោកបានបដិសេធ
ហើយសូមតែសំលៀកបំពាក់អ៊ីម៉ាំមួយប៉ុណ្ណោះទុកជាអនុស្សាវរីយ៍ ។ អ៊ីម៉ាំ
បានឲ្យអាវក្រៅព្រះអង្គទៅដ្វាក្ក់បាល់ ដ្វាក្ក់បាល់ទទួលយកដោយអរព្រះ
គុណព្រះអង្គហើយក៏បានចាកចេញ ។

## ជាមួយពួកចោរ

សម័យពួកអ្ញាប់បាស់សម្បូរក្រុមចោរណាស់ ។ ភាគច្រើនប្លន់តែឈ្មួញនិង
អ្នកដំណើរសំណព្វរបស់រាជអំណាច ។ កាលដ្វាក្ក់បាល់បានធ្វើដំណើរទៅឯ
ទិសខាងលិចក្បួនទូរចរលោកត្រូវក្រុមចោរប្លន់ យកអស់របស់របរដែលមាន
ក្នុងក្បួនទូរចរនោះ ។ ពេលពួកចោរកំពុងចែកអីវ៉ាន់គ្នា ចោរម្នាក់បានសូត្រ
កំណាព្យរបស់ដ្វាក្ក់បាល់ៗឆ្ងៀតយកឱកាសបង្ហាញខ្លួន ។ លុះពួកចោរបាន
ស្គាល់លោក ពួកគេបានឲ្យរបស់របរលោកដែលពួកគេបានប្លន់យកទាំងអស់
នោះមកលោកវិញ ។ ការពិតកំណាព្យដែលដ្វាក្ក់បាល់បានសូត្រឲ្យអ៊ីម៉ាំស្តាប់
នោះបានលេចឮទៅក្នុងចំណោមសំណាក់មុស្លីមទាំងឡាយ ហើយបានឮមក
ដល់ក្រុមចោរដែរ ។ កាព្យមួយឃ្លាដែលចោរបានសូត្រនោះមកពីកំណាព្យ







صلوات الله عليه والسلام បានសូមឲ្យខ្ញុំមកជួប បានឲ្យគេយកយានជំនិះមកដឹកខ្ញុំទៅជួបព្រះអង្គ ។ យើងបានអង្គុយជជែកគ្នា ហើយបានទទួលទានបាយពេលល្ងាច ។ បន្ទាប់ពីនោះព្រះអង្គបានស្នើឲ្យខ្ញុំសម្រាកយប់នៅទីនោះ ឯកនហាលខាង លើផ្ទះដែលយើងកំពុងតែអង្គុយនោះ ។ ខ្ញុំយល់ព្រម ព្រះអង្គបានឲ្យជួយខ្ញុំ ហើយចុះទៅវិញបន្ទាប់ពីបានលាខ្ញុំថារាត្រីសួស្តី ។ ខ្ញុំនឹកក្នុងចិត្តថា៖ «ខ្ញុំបានទទួលកិត្តិយសពីអ៊ីម៉ាំជាងគេទាំងអស់ ។» ខ្ញុំក៏ដឹងខ្លួនថាមានអាការក្រអឺត ។ ព្រឹកឡើង អ៊ីម៉ាំបានលាខ្ញុំ បានចាប់ស្មាខ្ញុំហើយមានវចនៈថា៖ «ព្រះអគ្គមហាប្រមុខ صلوات الله عليه والسلام របស់អ្នកមានសទ្ធាបានទៅលេង សុក់ស៏អ៊ាស៊ ប៊ិន ស៊ោហាន (صعصعة بن صوحان) កាលលោកឈឺ ។ មុនព្រះអង្គ صلوات الله عليه والسلام ត្រឡប់វិញ ព្រះអង្គ صلوات الله عليه والسلام មានវចនៈថា៖ «សុក់ស៏អ៊ាស៊អឺយ ចូរកុំក្រអឺតដាក់បងប្អូនលោកព្រោះតែខ្ញុំមកមើលលោកនោះ ។» ហាក់ដូចជាព្រះអង្គមើលឃើញចិត្តលោកច្បាស់ទែងតែម្តង ។ នេះគ្រាន់តែជាឥទ្ធិឫទ្ធិបន្តិចបន្តួចប៉ុណ្ណោះរបស់អ៊ីម៉ាំ តែអ្វីដែលយើងយកចិត្តទុកដាក់ត្រង់នេះគឺវិធីសាស្ត្រដែលអ៊ីម៉ាំប្រើ ដើម្បីឃាត់សាវកភ័ក្តីរបស់ព្រះអង្គកុំឲ្យធ្លាក់ខ្លួនទៅក្នុងអាការក្រអឺត ។



ទាយាទស្របច្បាប់របស់ព្រះសាស្តា صلى الله عليه وآله وسلم ។

## កំណាព្យមួយឃ្លារបស់អ៊ីម៉ាំ صلوات الله عليه والسلام

លុះកំណាព្យរបស់ដាក់ប៊ាល់បានរៀបរាប់ដល់ផ្ទូរក្រោយបង្អស់ អ៊ីម៉ាំ អាររីដ្ហ៏ صلوات الله عليه والسلام បានកាត់សម្តីដាក់ប៊ាល់ដើម្បីបន្ថែមកាព្យមួយឃ្លាគឺ៖

"ផ្ទូរមួយនៅឯទុស ។ ទុក្ខព្រួយ អកុសល
ញាំញីក្នុងទ្រូងឥតល្ហែ ។ ឈឺចាប់មិនអាចទ្រាំបាន ។"

ដាក់ប៊ាល់ឆ្ងល់ណាស់ បានសួរអ៊ីម៉ាំថាតើព្រះអង្គចង់និយាយអំពីផ្ទូរមួយណា ? អ៊ីម៉ាំបានតបថាព្រះរាជសពព្រះអង្គនឹងត្រូវបញ្ចុះនៅឯស្រុកទុសមិនយូរទេ ។ អ៊ីម៉ាំបានប្រាប់ឲ្យដឹងជាមុនអំពីព្រះទុក្ករកម្មព្រះអង្គ ។ នៅក្នុងវគ្គទីពីររបស់កំណាព្យនេះ គេឃើញមានសេចក្តីបញ្ជៀងសំដៅឧបករណ៍ក្នុងឃាតកម្មព្រះអង្គ គឺថ្នាំបំពុល ។

ដាក់ប៊ាល់សូត្រកំណាព្យតទៀត រៀបរាប់អំពីគុណសម្បត្តិរបស់អាស្ហ-លុលបៃត្ហ៏ عليهم السلام និងអំពើអយុត្តិធម៌ដែលព្រះអង្គ عليهم السلام ទាំងអស់ទទួលរង ។ ព្រះរាជសវនាការបានក្លាយទៅជាពិធីកាន់ទុក្ខ ។ អ្នកចូលគាល់ទាំងឡាយបានយំ

ដែលមិនស័ក្តិសមនឹងបានកំណាព្យនោះ ។ ដាក់ុំបាល់ អាល់-ឃូសាុអ៊ី (دعبل بن علي الخزاعي) ជាកវីម្នាក់ ក្នុងចំណោមកវីដ៏កម្រទាំងនោះ ស្មោះត្រង់ និងប្តេជ្ញាចិត្ត ។ អាស្រ័យកំណាព្យរបស់លោក លោកបានរក្សាទុកឲ្យប្រវត្តិសាស្ត្រនូវគុណសម្បត្តិមួយចំនួន និងឧបការគុណរបស់អាស់លុល-ប៉ៃត៍ صلوات الله عليه والسلام ។

## ដាក់ុំបាល់ជួបអ៊ីម៉ាំ صلوات الله عليه والسلام

កាលអ៊ីម៉ាំអារីដ្ហ៏ صلوات الله عليه والسلام នៅឯម៉ារូ ដាក់ុំបាល់បានទៅលេងព្រះអង្គ ។ អ៊ីម៉ាំបានទទួលដាក់ុំបាល់ដោយសេចក្តីសោមនស្ស ។ ព្រះអង្គមានសេចក្តីរីករាយដែលបានស្តាប់កំណាព្យដែលលោកបានចងក្រងឡើង ហើយបានសូត្រជាគ្រាដំបូងឲ្យព្រះអង្គស្តាប់ ។ នេះគឺកំណាព្យដ៏អស្ចារ្យមួយដែលដាក់ុំបាល់ថ្លែងសរុបអំពីសោកនាដកម្មអាស់លុល-ប៉ៃត៍ صلوات الله عليه والسلام ដោយរៀបរាប់អំពីផ្នូរអ៊ីម៉ាំអាស់លុល-ប៉ៃត៍ صلوات الله عليه والسلامម្តងមួយៗ ដាស់សតិអារម្មណ៍ឲ្យនឹកដល់ព្រះអង្គគ្រប់អង្គ អញ្ជើញបេះដូងអ្នកមានវត្តមាននៅទីនោះឲ្យមើលឃើញទំហំមហន្តរាយរបស់សំណាក់មុស្លីម គឺមហន្តរាយដែលនៅក្នុងចំណោមទង្វើអយុត្តិធម៌ និងការកាប់សម្លាប់ជាបន្តបន្ទាប់ដែលបានប្រព្រឹត្តមកលើព្រះ



## សៃដ៍ ប្អូនរបស់អ៊ីម៉ាំ صلوات الله عليه والسلام

អ៊ីម៉ាំអារីដ្ហ៏ صلوات الله عليه والسلامមានប្អូនម្នាក់ឈ្មោះសៃដ៍ ដែលបានធ្វើបដិវត្តន៍បង្ហូរឈាមនៅឯស្រុកបាស្វ៉ោះត្រ៍ ដោយបានប្រព្រឹត្តអំពើព្រៃផ្សៃដែលសាសនាអ៊ីស្លាមហាម ។ សៃដ៍បានដុតបំផ្លាញផ្ទះសម្បែង ប្លន់ទ្រព្យអ្នកស្លូតត្រង់ដោយសំអាងថាជនអកុសលទាំងនេះចូលដៃខាងពួកអ៊ាប់បាស់ ។ សៃដ៍បានសាងកេរ្តិ៍ឈ្មោះអាក្រក់ដោយសារទង្វើទាំងនេះ ។ ប្រជារាស្ត្របានហៅសៃដ៍ថា សៃដ៍ភ្លើង (សៃដ៍ អាល់-ណារ) ។ ការបះបោររបស់សៃដ៍ត្រូវទ័ពរបស់អាល់-ម៉ាក់ុំមូនបង្ក្រាប ។ អាល់-ម៉ាក់ុំមូនព្រមទុកជីវិតសៃដ៍បើសៃដ៍ព្រមចុះចាញ់ ។

ប្រាកដណាស់ អ៊ីម៉ាំ អារីដ្ហ៏ صلوات الله عليه والسلامថ្កោលទោសការបះបោររបស់ប្អូនព្រះអង្គយ៉ាងដាច់អហង្ការ ។ ព្រះអង្គទ្រង់ពិរោធស្អានការណ៍កុបកម្មនេះ ។

កាលអាល់-ម៉ាក់ុំមូនបានតែងតាំងអ៊ីម៉ាំ អារីដ្ហ៏ صلوات الله عليه والسلامជាអ្នកស្នងអំណាចអាល់-ម៉ាក់ុំមូនាៗបានបញ្ជូនសៃដ៍ ប្អូនព្រះអង្គ មកឲ្យព្រះអង្គ ដើម្បីចង់ដឹងថាព្រះអង្គនឹងមានឥរិយាបថបែបណាខ្លះចំពោះសៃដ៍ ទំនងជាចង់ធ្វើឲ្យព្រះអង្គខ្មាស់គេ ។ អ៊ីមាំអារីដ្ហ៏ صلوات الله عليه والسلامមានវចនៈជាមួយសៃដ៍ថា៖ «សៃដ៍ អបមង្គលលើអ្នក ហេតុអ្វីអ្នកបង្ហូរឈាមនិងលួចប្លន់ ? អ្នកយល់ខុស







ស្វែងរកអំណាច លុះបានអំណាចហើយខិតខំតែការពារអំណាចនោះ មិនគ្រប់គ្រងដោយយុត្តិធម៌ទេ ។

៣- ប្រមូលមេដឹកនាំទាំងអស់ដែលចាត់ទុកជាអ្នកប្រឆាំងនោះ ជុំវិញអ៊ីម៉ាំអាររីដ្ហ៏ صلوات الله عليه والسلام នៅឯរាជធានីរបស់ពួកអាប់បាស់ ដើម្បីនឹងអាចគ្រប់គ្រងពួកគេទាំងអស់បាន បន្ទាប់ពីនោះនឹងអាចសម្លាប់ពួកគេបានតាមកាលៈទេសៈ ។

គោលដៅទាំងនេះមិនបានសម្រេចទេ ។ តែគោលដៅទីបីបានសម្រេចតែមួយប៉ែកប៉ុណ្ណោះគឺ៖ មានតែអ៊ីម៉ាំអាររីដ្ហ៏ صلوات الله عليه والسلام ព្រះអង្គឯងទេដែលបានទទួលទុក្ករកម្ម ព្រោះព្រះអង្គស្គាល់ផែនការរបស់អាល់-ម៉ាក់មូន ។ ចំណែកឯបណ្ដាសាវកភក្ដីនិងអ្នកគាំទ្រព្រះអង្គនៅមួយកន្លែង ។

## រឿងកវីម្នាក់

សម័យអ៊ីម៉ាំអាររីដ្ហ៏ صلوات الله عليه والسلام កំណាព្យជាឧបករណ៍ផ្សាយដំណឹងដែលគេស្គាល់ជាងគេ ហើយជាមធ្យោបាយដែលមានប្រសិទ្ធិភាពជាងគេក្នុងការញុំាងមតិសាធារណជន ជាពិសេសមតិអ្នកមានចំណេះ ។ កវីភាគច្រើនជាឈ្មួញលក់កំណាព្យឲ្យអ្នកណាដែលហ៊ានបង់ប្រាក់ច្រើន ។ កម្រមានណាស់ កវីដែលប្ដេជ្ញាស៊ូប្ដូររស់នៅយ៉ាងលំបាក ដោយមិនព្រមលក់កំណាព្យឲ្យអ្នកណា



ដោយសារពួកអ្នកស្រុកគូហ្វាស្អុ់មែនទេ ដែលបានអះអាងថាហ្វាទិម៉ាស្អុ់ អាស៊ុ់ស៊ុាស្អុ់រី سلام الله عليها បានហាមភ្លើងចំពោះកូនៗព្រះអង្គ سلام الله عليها ? ចូរអ្នកប្រយ័ត្នខ្លួន សម្ដីនេះមិនពាក់ព័ន្ធនឹងខ្ញុំនិងអ្នកទេ ។ សម្ដីដែលមានអត្ថន័យបែបនេះពាក់ព័ន្ធតែលើរូបអាល់-ហាសាន់ صلوات الله عليه والسلام និងអាល់-ហ៊ូសៃន៍ صلوات الله عليه والسلام ទេ ។ សូមស្បថចំពោះអល់ឡោះហ៍ عز وجل តែព្រះអង្គទាំងពីរ عليهم السلام ដែលស័ក្តិសមធ្វើបែបនេះ ក៏ព្រោះតែព្រះអង្គទាំងពីរ عليهم السلام អនុវត្តន៍តាមព្រះបញ្ញាអល់ឡោះហ៍ عز وجل ដោយឥតលក្ខខណ្ឌ ។ បើអ្នកគិតថាអ្នកអាចប្រព្រឹត្តបំពានព្រះបញ្ញាអល់ឡោះហ៍ عز وجل រួចហើយអាចចូលឋានសួគ៌បាននោះ បានសេចក្ដីថាអ្នកជាបុគ្គលជំនិតរបស់អល់ឡោះហ៍ عز وجل លើសអាល់-ហាសាន់ صلوات الله عليه والسلام អាល់-ហ៊ូសៃន៍ صلوات الله عليه والسلام លើសឪពុកអ្នក មូសា ប៊ិន យ៉ាក់ហ្វារ صلوات الله عليه والسلام និងខ្ញុំទៅទៀត ។» ស្ញុំបានទូលថា៖ «ទូលបង្គំជាប្អូនព្រះអង្គ ។» អ៊ីម៉ាំបានតបថា៖ «ដរាបណាអ្នកអនុវត្តន៍តាមអល់ឡោះហ៍ عز وجل ដរាបនោះអ្នកជាប្អូនខ្ញុំ ។ ណាប៊ីនុះហ៍ عليه السلام មានវចនៈថា៖ «ព្រះម្ចាស់ عز وجل អើយ កូនប្រុសទូលព្រះបង្គំជាខ្ញុំជាម្នាក់នៃគ្រួសារទូលព្រះបង្គំជាខ្ញុំ ។ ពាក្យសន្យារបស់ព្រះអង្គសច្ចៈពិតមែន ។ ព្រះអង្គមានយុត្តិធម៌ជាងអ្នកកាត់ក្ដីទាំងឡាយ ។ អល់ឡោះហ៍ عز وجل មានព្រះបន្ទូលចំពោះព្រះអង្គថា៖

«នុះហ្ន៍អឺយ គេមិនមែនជាម្នាក់នៃគ្រួសារអ្នកទេ ។ ការពិតគេជាអ្នកប្រព្រឹត្តទីទៃពីទង្វើល្អ (ស៊ូ.១១, អា.៤៥-៤៦) ។ សូមស្បថចំពោះអល់ឡោះហ្ទ៍ عزوجل ស៊ុៃដ្ឋ័អឺយ មិនមានអ្នកអាចបានអ្វីពីអល់ឡោះហ្ទ៍ عزوجل ដោយមិនគោរពព្រះអង្គ عزوجل និងមិនចុះចូលចំពោះព្រះអង្គ عزوجل នោះទេ ។»

មេរៀនដ៏វិសេសវិសាលនេះជាការបំភ្លឺយ៉ាងច្បាស់លាស់ ចំណុចមួយដែលអ្នកគាំទ្រអាស្ហ៍លុល-ៃបត៌ عليهم السلام មិនសូវយល់ ហើយដែលពួកសត្រូវរបស់អាស្ហ៍លុល-ៃបត៌ عليهم السلام ដែលសម្បូរឧបាយកលបានយកមកប្រើប្រាស់ គឺៈ ហេតុអ្វីបណ្ដាកូនចៅរបស់ព្រះសាស្ដា صلى الله عليه وآله وسلم មានឯកសិទ្ធិជាអ្នកជំនិតអល់ឡោះហ្ទ៍ عزوجل ជាងមុស្លីមឯទៀត ?

យើងបានស្ដីអំពីឌូអាអ៍ អាល់-នុដ្ជបាស្ហ៍ (دعاء الندبة) រួចមកហើយ ដែលជាចម្លើយមួយប៉ែករបស់សំណួរនេះ ។ ត្រង់នេះយើងបានទទួលចម្លើយទាំងស្រុងពីមាត់អ៊ីម៉ាំ អាររីដ្ឋ៍ صلوات الله عليه والسلام តែម្ដងគឺៈ «មិនមានអ្នកណាមួយទទួលបាននូវឯកសិទ្ធិពីអល់ឡោះហ្ទ៍ عزوجل ក្រៅពីតាមរយៈការគោរពសក្ការៈព្រះអង្គ عزوجل និងតាមរយៈការចុះចូលចំពោះព្រះអង្គ عزوجل នោះទេ ។ អ្នកណាមួយអះអាងថាខ្លួនជាជំនិតរបស់អល់ឡោះហ្ទ៍ عزوجل អាស្រ័យលើត្រកែសលោហិត ការពិតអ្នក



صلوات الله عليه والسلام បញ្ជាយ៉ាងគួរសមឲ្យព្រះអង្គត្រឡប់មកវិញថាៈ «បុត្រព្រះសាស្ដា صلى الله عليه وآله وسلم អល់ឡោះហ្ទ៍ عزوجل អឺយ អស់ទូលបង្គំបានធ្វើឲ្យព្រះអង្គនឿយហត់ខ្លាំង ។ អស់ទូលបង្គំចង់ឲ្យតែព្រះអង្គបានសម្រាកទេ ។ ដូច្នេះសូមព្រះអង្គវិលវិញ ។» អ៊ីម៉ាំបានបកក្រោយវិញ បណ្ដាលឲ្យមុស្លីមរាប់ពាន់នាក់ដែលកំពុងតែស្ងប់ស្ងែង ព្រោះតែព្រះអង្គមានបុកពាដូចព្រះសាស្ដា صلى الله عليه وآله وسلم និងរុងរឿងនោះឆ្ងល់និងមិនយល់អ្វីទាល់តែសោះ ។

## គោលដៅរបស់អាល់-ម៉ាក់មូន

គេអាចនិយាយសង្ខេបអំពីគោលដៅសំខាន់ៗ ក្នុងយុទ្ធនាការរបស់អាល់-ម៉ាក់មូនបានដូចតទៅគឺៈ

១– ធ្វើឲ្យរបបរបស់ខ្លួនមានបេរគោពមាំមួន ក្រោយពីមានសង្គ្រាមស៊ីវិលអស់រយៈពេលច្រើនឆ្នាំ ដោយបានបង្ក្រាបពួកអាឡាវីយ៉ាស្ហ៍(អ្នកស្រឡាញ់អាលី صلوات الله عليه والسلام)ដែលមិនហ៊ានរើបម្រាស់ប្រឆាំងរបបដែលមាន អ៊ីម៉ាំអាររីដ្ឋ៍ صلوات الله عليه والسلام ជាអ្នកស្នងអំណាចនោះឡើយ ។

២– យកឱកាសបង្ខូចឈ្មោះអាស្ហ៍លុល-ៃបត៌ عليهم السلام ដោយបង្ហាញឲ្យគេបានឃើញថាអាស្ហ៍លុល-ៃបត៌ عليهم السلام គ្រាន់តែជាអ្នកនយោបាយធម្មតាប៉ុណ្ណោះ ដែល





នោះជាជំនិតរបស់បិសាចជាងជំនិតរបស់អល់ឡោះហ៏ عزّ وجلّ ។»

## មហាសន្និបាតវិទ្យាសាស្រ្តនៅឯដំណាក់ស្តេចខ៏លិហ្វ

អាល់-ម៉ាក់មូនមានបំណងជំរុញអ៊ីមុាំទៅក្នុងស្ថានភាពស្មុគស្មាញមួយដែលព្រះអង្គមិនអាចយកជ័យជំនះបាន ។ ការពិតស្តេចខ៏លិហ្វគិតជាប្រជុំអ្នកមានប្រាជ្ញារបស់លទ្ធិផ្សេងៗ ដែលមិនមែនលទ្ធិអ៊ីស្លាមនៃសម័យរបស់ខ្លួននៅក្នុងអង្គប្រជុំតែមួយជាមួយអ៊ីមុាំ អារ៉ីដ្ហ៏ صلوات الله عليه والسلام អាចធ្វើឲ្យពន្លឺវិទ្យាសាស្រ្តរបស់អ៊ីមុាំសម័យកាលអាប់ឌិន ។ អាល់-ម៉ាក់មូនសង្ឃឹមថាអ៊ីមុាំនឹងពឹងផ្អែកលើពាក្យសំអាងទូទៅរបស់មុស្លីមទាំងឡាយ ពោលគឺ ពាក្យសំអាងដែលមានព្រះគម្ពីរគួរអាននិងហាឌីស្សបរិសុទ្ធជាមូលដ្ឋាន ឬដែលមានការរិះគិតដោយប្រើតក្កវិជ្ជាជាមូលដ្ឋាន ។ ពាក្យសំអាងប្រភេទនេះមិនមានប្រសិទ្ធិភាពទេចំពោះ... ទទួលនឹងពួកដែលបដិសេធដាច់អហង្ការទាំងព្រះគម្ពីរគួរអាន ទាំងហាឌីស្សបរិសុទ្ធម្យ៉ាងទៀតជនចំពួកនេះស្ទាត់ជំនាញខាងតក្កសាស្រ្ត ហើយបានត្រៀមខ្លួនជាស្រេចក្នុងការប្រើអាវុធដដែកបំភាន់ ដើម្បីយកជ័យជំនះក្នុងសម័យប្រជុំពិភាក្សាខាងវិទ្យាសាស្រ្ត ។

អ៊ីមុាំ អារ៉ីដ្ហ៏ صلوات الله عليه والسلام ស្គាល់គម្រោងការរបស់អាល់-ម៉ាក់មូនច្បាស់ ។ ស្តេច

ខ្ញុំលិហ្សរូបនេះជាបុគ្គលដែលស្គាល់ច្បាស់នូវចំនេះវិជ្ជានានា ក្នុងសម័យនោះ ។ អ៊ីមុាំបានរៀបចំយុទ្ធសាស្ត្រដែលមិនអាចទប់ទល់បានក្នុងការប្រយុទ្ធផ្លូវវិទ្យាសាស្ត្រនេះ គឺៈ ឆ្លើយតបលទ្ធិនីមួយតាមរយៈគម្ពីរដែលលទ្ធិនោះទទួលស្គាល់ និងយកសេចក្តីសំអាងរបស់លទ្ធិទាំងនោះមកប្រើទល់នឹងលទ្ធិទាំងនោះវិញ ។ យុទ្ធសាស្ត្រនេះមានជោគជ័យមែន អ៊ីមុាំ អាររីដ្ហ៍ صلوات الله عليه والسلام បានធ្វើឲ្យគូប្រឆាំងទាំងឡាយចុកមាត់អស់ ។ ប្រភពព័ត៌មានប្រវត្តិសាស្ត្រមួយចំនួនបានឲ្យដឹងថាអ្នកប្រាជ្ញាគ្រិស្ត យ៉ាហ៊្វូឌីនិងស្ហ៊ីប៊ីអ៊ីនខ្លះបានប្តូរសាសនាមកកាន់សាសនាអ៊ីស្លាម ព្រោះតែព្រមទទួលស្គាល់តម្លៃរបស់អ៊ីមុាំសម័យកាល ។ អ្វីដែលពិតប្រាកដនោះគឺ អ៊ិមរ៉ន ស្ហ៊ីប៊ីអ៊ីន ប្រតិភូក្នុងអង្គប្រជុំនោះបានសន្ទនាអំពីសាសនាយ៉ាងយូរជាមួយអ៊ីមុាំ អាររីដ្ហ៍ صلوات الله عليه والسلام នៅទីបញ្ចប់ក៏បានផ្លាស់សាសនា មកកាន់សាសនាអ៊ីស្លាមនៅក្នុងមហាសន្និបាតនេះតែម្តង ។ អ៊ីមុាំបានក្រាបប្រណិប័តន៍អរព្រះគុណអល់ឡោះហ៊្ l عزّ وجلّ ដែលបានទទួលជោគជ័យដ៏ត្រចះត្រចង់មួយនេះ ។

## អ៊ីមុាំធ្វើដំណើរទៅកាន់ស្រុកម៉ារូ

ប្រហែលជាពិបាកយល់មូលហេតុពិត ដែលជំរុញអាល់-ម៉ាក់មូនឲ្យ



ជាសម័យប្រជុំមួយដ៏ធំក្នុងប្រវត្តិស្រុកនេះ ។ ប្រជារាស្ត្រស្រុកនេះនិងស្រុកជិតខាងធ្លាប់បានចូលរួមក្នុងស្ហ៊ូឡាត្ហ៍អ៊ីដ្ហច្រើនលើកមកហើយ ។ រៀងរាល់ដងពិធីនេះមានភាពអធិកអធម ហើយជាឱកាសសម្រាប់ពួកអ្នកអាប់បាសដើម្បីបង្ហាញអំណាចខ្លួន ។ តែគ្រានេះខុសពីសព្វមួយដង ។ សំណាក់មុស្លីមភ្ញាក់ផ្អើលដែលបានឃើញថា ពិធីនេះមានភាពសាមញ្ញនិងភាពរុងរឿងតែម្តង ម្នាក់ៗ ចង់ចូលរួមក្នុងស្ហ៊ូឡាត្ហ៍ដំបូងបង្អស់របស់ព្រះរាជវង្សព្រះសាស្តា صلى الله عليه وآله وسلم ណាស់ ។

ចារបុរសរបស់ស្តេចខ្ញុំលិហ្សបានធ្វើរបាយការណ៍ភ្លាមៗ អំពីការប្រព្រឹត្តិទៅជាលំដាប់ ។ មុនអ៊ីមុាំ អាររីដ្ហ៍ صلوات الله عليه والسلام បានចាប់ផ្តើមបំពេញស្ហ៊ូឡាត្ហ៍ ស្តេចខ្ញុំលិហ្សក៏បានដឹងខ្លួនថាបានធ្វើខុសយ៉ាងធ្ងន់ ។ មែន នេះជាឱកាសសំខាន់មួយសម្រាប់ជួបនិងទំនាក់ទំនងគ្នារវាងអ៊ីមុាំនិងមុស្លីមរាប់ពាន់នាក់ ដែលនឹងអាចបានឃើញផ្ទាល់ភ្នែកព្រះទាយាទស្របច្បាប់ អ្នកស្នងព្រះរាជអំណាចរបស់ព្រះសាស្តា صلى الله عليه وآله وسلم ហើយជាឱកាសមួយដើម្បីប្រៀបធៀបភាពសាមញ្ញរបស់ព្រះអង្គជាមួយភាពអធិកអធមរបស់សន្តតិវង្សអាប់បាស់ ។ អាល់-ម៉ាក់មូនបានសម្រេចចិត្តបញ្ឈប់ការបំពេញស្ហ៊ូឡាត្ហ៍អ៊ីដ្ហ បានផ្ញើសារបន្ទាន់ទៅអ៊ីមុាំ អាររីដ្ហ៍

ស្ទ៏ឡាត្ត់រួម មិនមែនជាទង្វើនយោបាយដែលនៅក្នុងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនោះទេ ។ នៅទីបំផុតអ៊ីម៉ាំក៏បានយល់ព្រមដោយមានលក្ខខណ្ឌមួយគឺ៖ បំពេញស្ទ៏ឡាត្ត់ដូចព្រះសាស្តា صلى الله عليه وآله وسلم អល់ឡោះហ្ទ៍ عزوجل និងព្រះអគ្គមហាប្រមុខរបស់អ្នកមានសទ្ធាធ្លាប់តែបំពេញ ។ អាល់-ម៉ាក់មូនយល់ព្រម ហើយបានបញ្ជាឲ្យមេបញ្ជាការទ័ពទាំងអស់ទៅបំពេញស្ទ៏ឡាត្ត់អ៊ីដ្ឋ ពីក្រោយអ៊ីម៉ាំ អារីដ្ហ៍ صلوات الله عليه والسلام ។ ព្រឹកថ្ងៃបុណ្យអ៊ីដ្ឋ ប្រជារាស្ត្រស្រុកម៉ារូទាំងអស់បានចេញទៅស្ទ៏ឡាត្ត់ពីក្រោយអ៊ីម៉ាំសម័យកាល ។ អ្នកខ្លះបានឡើងទៅស្ទ៏ឡាត្ត់លើរានហាលផ្ទះខ្លួន ។ ពិធីបុណ្យនេះជាពិធីបុណ្យមួយដែលគេមិនធ្លាប់ឃើញទេ ។ អ៊ីម៉ាំបានងូតទឹកជម្រះព្រះកាយ បានលាបទឹកអប់ ហើយបានជួតក្បាលដោយឈ្នួតស ទម្លាក់ចុងឈ្នួតមួយលើទ្រូង ចុងមួយទៀតចន្លោះស្មាទាំងពីរ បានកាន់ឈើច្រត់ បានបញ្ជាឲ្យសាវកនិងអ្នកបម្រើទាំងឡាយរបស់ព្រះអង្គធ្វើបែបនេះដែរ ហើយបានយាងដោយជើងទទេទៅកាន់មាត់ទ្វារ ។ លុះពួកមេបញ្ជាការទ័ពទាំងអស់បានឃើញព្រះអង្គ ក៏បានចុះមកឯដីហើយបានដោះស្បែកជើង ។ លុះអ៊ីម៉ាំសូត្រថា៖ “អល់ឡ៏ហ៊្វូអាក់បារ” ទាំងអស់គ្នាបានសូត្រតាម ។ អ្នកដែលនៅក្នុងផ្ទះនៅឡើយម្នីម្នារត់មកកាន់ក្បួនដ៏សម្បើម ។ នេះ



តែងតាំងអ៊ីម៉ាំ អារីដ្ហ៍ صلوات الله عليه والسلام ជាអ្នកស្នងរាជបល្ល័ង្ករបស់ខ្លួន ។ ទោះជាយ៉ាងណាក៏ដោយ ចំណុចដែលជាក់ច្បាស់នោះគឺមានពីរ ។ ចំណុចទីមួយគឺ ផ្ទុយពីអាការក្រៅ អាល់-ម៉ាក់មូនមិនព្រមទទួលស្គាល់អំណាចខាងសាសនារបស់អាស្ទ់លុល-បៃត៍ عليهم السلام យ៉ាងពិតប្រាកដទេ ចំណែកឯការស្នើសូមលាពីតំណែងរបស់អាល់-ម៉ាក់មូន ដើម្បីផ្ទេរតំណែងនោះឲ្យទៅ អ៊ីម៉ាំ អារីដ្ហ៍ صلوات الله عليه والسلام នោះវិញគ្រាន់តែជាកាយវិការនយោបាយមួយ ដែលមានការប្រថុយប្រថានដែលគិតទុកមុនជាស្រេចហើយតែប៉ុណ្ណោះ ។ ចំណុចទីពីរគឺ អាល់-ម៉ាក់មូនខ្វះភាពស្របច្បាប់ច្រើនណាស់ ពីព្រោះបុគ្គលរូបនេះអាចឡើងកាន់អំណាចបានដោយសារតែបានធ្វើសង្គ្រាមស៊ីវិលបង្ហូរឈាម និងដោយសារតែបានធ្វើឃាតបងបង្កើតរបស់ខ្លួន អតីតស្តេចខ៏លិហ្វ ។ ទង្វើទាំងនេះមិនអាចធ្វើឲ្យគោលជំហររបស់បុគ្គលរូបនេះមានភាពមាំមួនទេ ប្រឈមនឹងពួកអុាប់បាស់ឯទៀត ឬប្រឈមនឹងសំណាក់មុស្លីមឯទៀតតែម្តង ។

អាល់-ម៉ាក់មូនត្រូវការពំនាក់ ដើម្បីធ្វើឲ្យអំណាចខ្លួនទៅជាអំណាចស្របច្បាប់ ។ ដូច្នេះបុគ្គលរូបនេះបានស្នើសូមឲ្យអ៊ីម៉ាំអារីដ្ហ៍ صلوات الله عليه والسلام ដែលជាបុគ្គលស្របតាមច្បាប់អល់ឡោះហ្ទ៍ عزوجل និងច្បាប់មនុស្ស ព្រមឡើងកាន់អំណាច





សន្តតិវង្ស ។ សំណាក់មុស្លីមបានប្ដេជ្ញាស្មោះស្ម័គ្រចំពោះអ៊ីមុាំ អាររីដ្ហ៏ صلوات الله عليه والسلام ក្នុងឋានៈជាអ្នកស្នងអំណាចខ៏លីហ្វាស្ទ់ ។ ពិធីនេះបានប្រព្រឹត្តទៅថ្ងៃទី ៥ ខែរ៉ម៉ាដូន ឆ្នាំ ២០១ សករាជហ៊ិជ្ជរ៉ោះត្ទ័ ។ គេបានបោះប្រាក់ក្នុងព្រះនាមអ៊ីមុាំ មនុស្សទាំងអស់បានចោលសំលៀកបំពាក់ពណ៌ខ្មៅ ដែលនិមិត្តសញ្ញារបស់ពួកអ្នាប់បាស់ មកស្លៀកពាក់ពណ៌បៃតងវិញ ដែលជានិមិត្តរូបរបស់ពួកពែរស៍សាសានីយ៉ាស្ទ់ (الساسانية) និងជានិមិត្តរូបរបស់អាស្ទ់លុល-បៃត៌ صلوات الله عليه والسلام ដែរ ។

អ៊ីមុាំគ្រាន់តែជាសាក្សីចំពោះព្រឹត្តិការណ៍ទាំងនេះទេ ព្រះអង្គបានរំលឹកប្រាប់បណ្ដាសាវកភ័ក្ដីព្រះអង្គ គ្រប់ឱកាស ថាព្រះអង្គត្រូវបង្ខំឲ្យបិទមាត់ ។

## នមស្ការអ៊ីដូ

២៥ ថ្ងៃក្រោយពិធីបៃអ្នាស្ទ់(بيعة ការប្ដេជ្ញាស្មោះស្ម័គ្រ) អាល់-ម៉ាក្មុំមូនបានសូមឲ្យអ៊ីមុាំ អាររីដ្ហ៏ صلوات الله عليه والسلام ដឹកនាំស៊្ហឡាត្ទ់ អ៊ីដូ អាល់-ហ្វិត្ទរ៍ ។ អ៊ីមុាំបានបដិសេធ ហើយបានរំលឹកអាល់-ម៉ាក្មុំមូនឡើងវិញអំពីលក្ខខណ្ឌដែលព្រះអង្គបានដាក់ហើយនោះដើម្បីទៅជាអ្នកស្នងបុរសរូបនេះ ។ តែអាល់-ម៉ាក្មុំមូននៅតែទទូចសូម បានចាត់បញ្ជូនអន្តរការីទៅធ្វើឲ្យអ៊ីមុាំព្រមជឿថាដឹកនាំ

ផាយាទេ ។ ការប្រកាសលាលែងពីអំណាចគ្រាន់តែជាការបញ្ឆោតដើម្បីទទួលបាននូវចំណូលចិត្តពីសំណាក់មុស្លីម ដែលធុញទ្រាន់បុគ្គលសាហាវឃោរឃៅស្រេកឃ្លានអំណាច ។ តែការស្នើសូមទីពីររបស់អាល់-ម៉ាក់មូន ដែលជាសំណូមពរគំរាមកំហែងនោះជាឧបសគ្គធំសម្រាប់អ៊ីម៉ាំ ។ ព្រះអង្គចាំបាច់ត្រូវធ្វើជាព្រមទទួលសំណូមពរនោះ ដោយដឹងថាព្រះជន្មព្រះអង្គកាន់តែខ្លីទៅៗ នៅទីបំផុតព្រះអង្គដូចអ្នកមុនៗដែរ គឺត្រូវធ្វើគុតដោយដៃបុគ្គលសាហាវយង់ឃ្នងតែមួយនេះ ដែលធ្វើពុតជាប្រគល់អំណាចមកឲ្យព្រះអង្គនៅលើជាសមាស ។

អ៊ីម៉ាំព្រមទៅជាអ្នកស្នងអំណាចរបស់ពួកអាប់បាស់ដោយសន្មត់នោះ ក៏ប៉ុន្តែព្រះអង្គបានដាក់លក្ខខណ្ឌមួយដែលបញ្ជាក់ឲ្យឃើញថា ព្រះអង្គមិនព្រមទទួលស្គាល់អំណាចខុសច្បាប់របស់ត្រកូលនេះជាដាច់ខាត គឺព្រះអង្គមិនព្រមលូកដៃក្នុងអំណាចជាដាច់ខាត ។ ដូច្នេះព្រះអង្គជា “ព្រះរាជទាយាទ” មួយគត់ក្នុងលោកដែលមិនពាក់ព័ន្ធជាមួយអំណាចនិងកិច្ចការនយោបាយ ។ គេមិនដែលជួបប្រទះគោលជំហររបស់អនាគតព្រះរាជទាយាទស្នងអំណាចណាមួយដូចនេះទេ នៅក្នុងលោកនេះ ក្នុងគ្រប់



មិនដូច្នោះទេឲ្យព្រះអង្គព្រមទទួលឡើងកាន់អំណាចបន្ទាប់ពីខ្លួន ។ ការប្រថុយប្រថានត្រូវបានគិតទុកជាមុនជាស្រេចហើយ អាល់-ម៉ាក់មូនដឹងច្បាស់ថាអ៊ីម៉ាំអារីដ្ហ៍ صلوات الله عليه والسلام មិនអាចឡើងកាន់អំណាចបានទេ ព្រោះវានឹងធ្វើឲ្យខូចកេរ្តិ៍ឈ្មោះព្រះអង្គ صلوات الله عليه والسلام ចំពោះសហគមន៍មុស្លីមទាំងឡាយ ។

តែអ៊ីម៉ាំបានបដិសេធ ថែមទាំងបានបដិសេធមិនព្រមទៅជាអ្នកស្នងក្រោយអាល់-ម៉ាក់មូនទៀតផង ។ ការពិតការស្នើចុងក្រោយនេះអាក្រក់ជាងការស្នើដំបូងទៅទៀត ស្តេចខ៏លិហ្វបានបង្ខំឲ្យអ៊ីម៉ាំយល់ព្រមដោយគំរាមធ្វើគុតព្រះអង្គ ។

## ឆ្លងកាត់តាមស្រុកម៉ារ្វ

កាលអាល់-ម៉ាក់មូនកោះហៅអ៊ីម៉ាំមកកាន់ម៉ារ្វ ដែលជារាជធានីរបស់ខ្លួន ដើម្បីធ្វើការស្នើសូមឲ្យអ៊ីម៉ាំព្រមទទួលរាជ្យនោះ អ៊ីម៉ាំបានឆ្លងកាត់តាមស្រុកបាស្វ់ក៉ោះត្វ៍និងស្រុកគុម ។ អ្នកស្រុកទាំងអស់ ភាគច្រើនជាអ្នកគាំទ្រអាស្ហ់លុល-បៃត៍ عليهم السلام បានមកទទួលព្រះអង្គ ។ ផ្ទះដែលអ៊ីម៉ាំ អារីដ្ហ៍ صلوات الله عليه والسلام បានស្នាក់នៅមួយរយៈនៅឯស្រុកគុម នៅដល់សព្វថ្ងៃនេះហើយមានឈ្មោះថា “សាលា អារីដ្ហ៍វីយ៉ាស្ហ់” បញ្ជាក់ឲ្យឃើញថាពួកអ្នកស្រុកគុមស្មោះត្រង់

ចំពោះអ៊ីម៉ាំស្របច្បាប់របស់ខ្លួននិងចំពោះអាស្ហុលុល-ប៉ៃត៍ عليهم السلام ជាទូទៅ ។

## ស្រុកនីស្ហាប៊ូរ(نيشابور)

សម័យអ៊ីម៉ាំ អាររីដ្ហ៏ صلوات الله عليه والسلام នីស្ហាប៊ូរជាស្រុកវិទ្យាសាស្ត្រដ៏ធំមួយ ។ កាលអ៊ីម៉ាំយាងមកដល់ស្រុកនេះ ពួកអ្នកស្រុកបានមកទទួលព្រះអង្គយ៉ាងកក់ក្ដៅ ។ នាំមុខពួកគេមានអ្នកប្រាជ្ញល្បីៗរាប់សិបនាក់នៃសម័យនោះ មកចោមរោមអ៊ីម៉ាំដោយមានប៉ាកកានិងសន្លឹកក្រដាសគ្រប់ដៃ ដើម្បីកត់ត្រាសម្ដីព្រះអង្គ ។ ពួកគេបានទទូចសូមឲ្យព្រះអង្គថ្លែងហាឌីស្ហព្រះសាស្ដា صلى الله عليه وآله وسلم ខ្លះៗ ។ ពួកគេមួយចំនួនបានចាប់បង្ហៀរយានជំនិះព្រះអង្គ អង្វរព្រះអង្គតាមក្រសែព្រះបុព្វការី عليهم السلام សូមឲ្យព្រះអង្គមានវចនៈឲ្យពួកគេបានស្រង់ហាឌីស្ហមួយទុក ។ អ៊ីម៉ាំមានវចនៈឲ្យពួកគេសរសេរតាមថា៖ «ខ្ញុំបានឮមូសា صلوات الله عليه والسلام ព្រះបិតាខ្ញុំមានវចនៈតមកពីយ៉ាក់ហ្វារ صلوات الله عليه والسلام ព្រះបិតា صلوات الله عليه والسلام ព្រះអង្គ ដែលមានវចនៈតមកពីមូហាំម៉ាដ់ صلوات الله عليه والسلام ព្រះបិតា صلوات الله عليه والسلام ព្រះអង្គ ដែលមានវចនៈតមកពីអ៊ាលី صلوات الله عليه والسلام ព្រះបិតា صلوات الله عليه والسلام ព្រះអង្គ ដែលមានវចនៈតមកពីអាល់-ហ៊ូសែន صلوات الله عليه والسلام ព្រះបិតា صلوات الله عليه والسلام ព្រះអង្គ ដែលមានវចនៈតមកពី អ៊ាលី صلوات الله عليه والسلام ប៊ិន អាប៊ូ



គឺដីរបស់ខ្ញុំ កន្លែងបញ្ចុះសពខ្ញុំ ។ អល់ឡោះហ៊ូ عز وجل នឹងធ្វើឲ្យកន្លែងនេះទៅជាកន្លែងទស្សនកិច្ចសម្រាប់បណ្ដាអ្នកស្រឡាញ់ខ្ញុំ ។ សូមស្បថចំពោះអល់ឡោះហ៊ូ عز وجل អ្នកណាក្នុងចំណោមពួកគេបានមកលេងខ្ញុំកន្លែងនេះ អល់ឡោះហ៊ូ عز وجل នឹងខមាទោសឲ្យអ្នកនោះ ។ យើង عليهم السلام អាស្ហុលុល-ប៉ៃត៍ عليهم السلام ធ្វើអន្តរាគមន៍ឲ្យអ្នកនោះ ។» បន្ទាប់មកព្រះអង្គបានបំពេញនមស្ការពីររ៉ាក់អ៊ាត់ បានក្រាបប្រណិប័តន៍យ៉ាងយូរ បានសូត្រថ្វាយសេចក្ដីសរសើរចំពោះអល់ឡោះហ៊ូ عز وجل ប្រាំរយដងក្នុងការក្រាបប្រណិប័តន៍នេះ ។

## ស្រុកម៉ារូ

អ៊ីម៉ាំបានមកដល់ស្រុកម៉ារូ រាជធានីរបស់អាល់-ម៉ាក់មូន ។ ស្ដេចខ៊្លិហ្វផ្ទាល់បានចេញមកទទួលព្រះអង្គ បានសម្ដែងសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់និងសេចក្ដីលើកតម្កើងដ៏លើសលុបចំពោះអ៊ីម៉ាំសម័យកាល នៅចំពោះមុខប្រជារាស្ត្រនៃរាជធានីម៉ារូ ។

## អ៊ីម៉ាំនិងអំណាច

អ៊ីម៉ាំ អាររីដ្ហ៏ صلوات الله عليه والسلام ដឹងច្បាស់ថា អាល់-ម៉ាក់មូនមិនលាលែងពីអំណាច







តលិប رضي الله عنه ព្រះបិតា صلوات الله عليه والسلام ព្រះអង្គ ដែលមានវចនៈថា ខ្ញុំបានឮព្រះសាស្ដា صلى الله عليه وآله وسلم មានព្រះវចនៈតមកពីយ៉ីបរ៉អ៊ីល عليه السلام ដែលមានវចនៈថា ខ្ញុំបានឮអល់ឡោះហ៊្វ عز وجل មានព្រះបន្ទូលថា៖ រូបមន្ត "ពុំមានព្រះទេក្រៅពីអល់ឡោះហ៊្វ عز وجل" ជាបន្ទាយរបស់អញ عز وجل ។ អ្នកណាចូលមកក្នុងបន្ទាយអញ عز وجل អ្នកនោះរួចផុតពីទណ្ឌកម្មអញ عز وجل ។» អ៊ីម៉ាំអារីដ្ឋ صلوات الله عليه والسلام បានបន្ថែមថា៖ «ព្រមទាំងគោរពលក្ខខណ្ឌមួយចំនួន ។ ខ្ញុំជាលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌទាំងនោះ ។» គេហៅហាឌីស្ហនេះថាហាឌីស្ហយោលតាមបណ្ដាញមាស (سلسلة الذهبية) ពីព្រោះបុគ្គលទាំងអស់ដែលគេបានទទួលយកព័ត៌មានមក ដែលឡើងទៅដល់អល់ឡោះហ៊្វ عز وجل នោះជាបុគ្គលប្រសើរលើសគេទូទាំងសម័យទាំងអស់ ។ អ្នកប្រវត្តិសាស្ត្របានប្រមាណចំនួនអ្នកកត់ត្រាហាឌីស្ហ នេះថាមានចំនួន ២០០០០ បញ្ជាក់ឲ្យឃើញថាសំណាក់មុស្លីមគោរពអ៊ីម៉ាំ អារីដ្ឋ صلوات الله عليه والسلام ណាស់ ។

## អព្ភូតហេតុទឹក

ព្រឹកបន្ទាប់មក អ៊ីម៉ាំបានចាកចេញពីនីស្ហាប៊ូរ ឆ្ពោះទៅកាន់ម៉ារូ ។ លុះថ្ងៃជ្រេបន្តិច អ៊ីម៉ាំបានឈប់ដើម្បីបំពេញនមស្ការតែគេបានប្រាប់ព្រះអង្គថាមិនមានទឹកដើម្បីយកទឹកវូឌុអ៊ូទេ ។ អ៊ីម៉ាំក៏បានធ្វើឲ្យមានទឹកចេញមកពីក្នុងដី ។



ព្រះអង្គបានយកទឹកវូឌុអ៊ូពីប្រភពទឹកចេញនោះ ។ គេក៏បានយកទឹកវូឌុអ៊ូក្រោយព្រះអង្គដែរ ។ ស្លាកស្នាមនៃអព្ភូតហេតុនេះនៅតែមានរហូតមកដល់សព្វថ្ងៃនេះ ។

## ឆ្នាំងស្រុកសាណា អាបាដ់

អ៊ីម៉ាំបានបន្តដំណើរលុះបានមកដល់ស្រុកមួយដែលហៅថា សាណាអាបាដ់ ។ ព្រះអង្គឃើញមានភ្នំមួយនៅទីនេះ ពួកអ្នកស្រុកយកដីភ្នំនេះធ្វើឆ្នាំង ។ អ៊ីម៉ាំបានបួងសួងអល់ឡោះហ៊្វសូមព្រះអង្គប្រសិទ្ធពរដល់ភ្នំនេះ ហើយបានជាវឆ្នាំងពីរបីសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ។

## ស្រុកទុស(توس)

នៅក្បែរស្រុកទុស អ៊ីម៉ាំបានចូលទៅក្រោមដោមដែលគេបានសាងនៅពីលើផ្នូររបស់ហារូន អាររ៉ស្ហីដ ។ ព្រះអង្គបានប្រាប់សាវកព្រះអង្គទាំងឡាយថាព្រះរាជសពព្រះអង្គនឹងត្រូវបញ្ចុះនៅទីនេះឯង ។ ព្រះអង្គបានគូសខ្សែត្រង់កន្លែងដែលមានផ្នូរព្រះអង្គសព្វថ្ងៃនេះ ហើយមានវចនៈថា៖ «ត្រង់នេះ